# ខេត្តាស្ថានស្លឹករឹត
## វិទ្យាស្ថានសិក្សាពីអំពើប្រល័យពូជសាសន៍ ជម្លោះ និង សិទ្ធិមនុស្ស

បាឋកថាស្តីអំពី
**ចលនសម្បត្តិវប្បធម៌ ៖ បញ្ហាប្រឈម និងដំណោះស្រាយ**
ដោយសាស្ត្រាចារ្យ សេង សោត

ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៥ វេលាម៉ោង ២:៣០ នាទី ដល់ម៉ោង ៤:៣០ នាទី រសៀល
នៅអគារ H នៃវិទ្យាស្ថានជាតិអប់រំ

វិទ្យាស្ថានសិក្សាអំពី អំពើប្រល័យពូជសាសន៍ ជម្លោះ និងសិទ្ធិមនុស្សនៃវិទ្យាស្ថានស្លឹករឹត សូមជូនដំណឹងថា វិទ្យាស្ថាននឹងរៀបចំបាឋកថាស្តីអំពី *ចលនសម្បត្តិវប្បធម៌ ៖ បញ្ហាប្រឈម និងដំណោះស្រាយ* ដែលបង្ហាញដោយ លោកសាស្ត្រាចារ្យ **សេង សោត** អគ្គនាយករងនៃនាយកដ្ឋានរដ្ឋបាលទូទៅសម្រាប់ការអភិរក្សន៍ និងការពារធម្មជាតិនៃក្រសួងបរិស្ថាន។ បាឋកថានេះនឹងប្រព្រឹត្តិឡើងនៅ ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៥ វេលាម៉ោង ២:៣០ នាទី ដល់ម៉ោង ៤:៣០ នាទី រសៀល នៅអគារ H នៃវិទ្យាស្ថានជាតិអប់រំ។ សិស្ស និសិត្ស គរុសិស្ស និងសាធារណជនអាចចូលរួមបានដោយសេរី។

កម្ពុជាបច្ចុប្បន្នជាប្រទេសដែលមានទំហំផ្ទៃដីតូច និងមានចំនួនប្រជាជនតិច បើប្រៀបធៀបជាមួយបណ្តាប្រទេសនៅក្នុងសមាគមអាស៊ាន។ ប៉ុន្តែ បើពិនិត្យឲ្យបានស៊ីជម្រៅ និងសិក្សាលម្អិតអំពីប្រវត្តិសាស្ត្រព្រះរាជាណាចក្រកម្ពុជា ជាប្រទេសដែលមានអារ្យធម៌ខ្ពង់ខ្ពស់ និងវប្បធម៌យូរលង់ដែលដូនតាខ្មែរបានខិតខំច្នៃបង្កើតឡើង តាមរយៈស្នាដៃដ៏វិសេសវិសាល និងសម្បូរបែប ដើម្បីបម្រើឲ្យសង្គមគ្រួសារខ្មែររាប់ជំនាន់តរៀងមក។ តាមរយៈស្នាដៃ ឬមរតកវប្បធម៌រូបី និងអរូបីទាំងនោះ កម្ពុជាទទួលបាននូវភាពល្បីល្បាញនៅលើសាកលលោក ជាពិសេស បន្ទាប់ពីតំបន់អង្គរត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកកាលពីឆ្នាំ ១៩៩២។ ទោះជាយ៉ាងណា ក្នុងរយៈកាលជាងមួយសតវត្សចុងក្រោយនេះ កម្ពុជាបានឆ្លងកាត់នូវសង្គ្រាមរាំរ៉ៃ ស្ថិតនៅលើកំណាត់ផ្លូវដ៏លំបាក និងស្មុគស្មាញ ដោយបញ្ហាអស្ថេរភាព និងអសន្តិសុខដែលបានផ្តល់ឱកាសដល់ជនទុច្ចរិតអគតិលួចជីកគាស់កកាយ ជាប់បំផ្លាញ និងលួចនាំយកចលនសម្បត្តិវប្បធម៌ដ៏មានតម្លៃចេញពីប្រទេសកម្ពុជា។

វាគ្មិននឹងបកស្រាយអំពីដើមហេតុដំបូងៗដែលនាំទៅដល់ការកើតមានការបំផ្លាញ និង ការធ្វើឲ្យបាត់បង់ចលនសម្បត្តិវប្បធម៌ពីព្រះរាជាណាចក្រកម្ពុជា ព្រមទាំងនឹងមានការលើកឡើងនូវយន្តការសំខាន់ៗដែលមានប្រយោជន៍សម្រាប់កម្ពុជាក្នុងការទប់ស្កាត់ និងការបញ្ឈប់ការធ្វើចរាចរសម្បត្តិវប្បធម៌ដោយខុសច្បាប់។ លោកសាស្ត្រាចារ្យ **សេង សោត** គឺជាអគ្គនាយករងនៃនាយកដ្ឋានរដ្ឋបាលទូទៅសម្រាប់ ការអភិរក្សន៍ និងការពារធម្មជាតិនៃក្រសួងបរិស្ថាន និងជាអតីតសាស្ត្រាចារ្យផ្នែកបុរាណវិទ្យានៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។ លោកសាស្ត្រាចារ្យបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតពីសាកលវិទ្យាល័យ Senghor ប្រទេសអេហ្ស៊ីប ផ្នែកគ្រប់គ្រងបេតិកភណ្ឌវប្បធម៌។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖
ម៉ែន ពិចិត្រ
សាមេឌ្ជីនៃការចងចាំ
truthmpechet@dccam.org
ទូរសព្ទ +៨៥៥ ២៣ ២១១ ៨៧៥